ខុមហ្វ្រែល COMFREL GADC សមាគមអាដហុក ADHOC YRDP HRTF

ភ្នំពេញ, ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា មានកិត្តិយសជម្រាបជូនសាធារណជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូតឲ្យបានជ្រាបថា នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៤ ញត្តិស្តីពីការកំណត់អាណត្តិនាយករដ្ឋមន្ត្រី ដែលក្នុងដំណាក់កាលទី០១មានការគាំទ្រចំនួន ១១៩០នាក់ ពីប្រជាពលរដ្ឋ សិស្ស និស្សិត ព្រះសង្ឃ និងអ្នកជំនាញឯករាជ្យ ព្រមទាំងតំណាងអង្គការសង្គមស៊ីវិលនៅកម្ពុជា ត្រូវបានដាក់ជូន ថ្នាក់ដឹកនាំកំពូលនៃរដ្ឋសភា (ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២) និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ដោយឡែក លិខិតដែលដាក់ជូនសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងញត្តិទាមទារការកំណត់អាណត្តិនាយករដ្ឋមន្ត្រីនេះ ក៏ត្រូវបានចម្លងជូនតំណាងរាស្ត្រចំនួន ១១៩ ផ្សេងទៀតផងដែរ។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា នឹងបន្តប្រមូលការគាំទ្រញត្តិនេះ ហើយដាក់ជូនថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាលនាពេលបន្តបន្ទាប់។

សូមសាធារណជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូត ជ្រាបជាព័ត៌មាន៕

ព័ត៌មានបន្ថែមសូមទាក់ទង៖

០៨៩ ២១ ២១ ១០